# ព្រឹត្តិបត្រប្រចាំត្រីមាសទី១

ទឹកស្អាតសម្រាប់មនុស្សគ្រប់រូប

ខែមករា ដល់ ខែមីនា ឆ្នាំ២០២៣

## ១. បច្ចុប្បន្នភាពសមាគម

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ជាសមាគមអព្យាក្រឹត មិនស្វែងរកប្រាក់កម្រៃជាឯកជនមិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើនយោបាយ មិនធ្វើជាឧបករណ៍របស់គណបក្សនយោបាយ ក្នុងនោះមិនផ្តល់ជាសម្ភារ ហិរញ្ញវត្ថុ ធនធានមនុស្ស ដើម្បីគាំទ្រគណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រណាមួយឡើយ។ សមាគមបម្រើឱ្យផលប្រយោជន៍សមាជិក និងផលប្រយោជន៍សាធារណៈតាមលទ្ធភាពដែលសមាគមអាចចូលរួមបាន។

សមាគមបង្កើតឡើងនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១ ដោយក្រុមអ្នកផ្គត់ផ្គង់ទឹកស្អាតឯកជនមួយក្រុមមានគ្នាប្រមាណជា ២០នាក់ ក្រោមជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ របស់គម្រោង អេម អេស អេម អ៊ី កម្ពុជា (MSME) ឧបត្ថម្ភដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) និងបានចុះបញ្ជីសមាគមជាផ្លូវការនៅក្រសួងមហាផ្ទៃ តាមសេចក្តីជូនដំណឹងលេខៈ ១០៧៧ សជណ របស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១២។ ក្រសួងមហាផ្ទៃចេញសេចក្តីប្រកាសលេខៈ ២៩០១ ប្រក ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២១ សម្រេចចុះឈ្មោះសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ឡើងវិញក្នុងបញ្ជីសមាគមសម្រាប់នីតិបុគ្គល នៅក្រសួងមហាផ្ទៃ ដោយមានអាសយដ្ឋាននៃទីស្នាក់ការកណ្តាលស្ថិតនៅអគារ F ជាន់ទី២ បន្ទប់លេខ ២៦៩ នៃមជ្ឈមណ្ឌលភ្នំពេញ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

សមាគមបង្កើតឡើងក្នុងគោលបំណងប្រមូលផ្តុំអ្នករួមអាជីព ឬរួមវិជ្ជាជីវៈទាំងអស់ក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនប្រកាន់និន្នាការនយោបាយអ្វីឡើយ។

គិតត្រឹមបំណាច់ត្រីមាសទី១ ឆ្នាំ២០២៣ សមាគមមានសមាជិកសរុបចំនួន ៣២៤ស្ថានីយ / ក្រុមហ៊ុនដែលបាននឹងកំពុងប្រតិបត្តិការនៅក្នុង ២៣រាជធានី/ខេត្ត/ក្រុង នៃព្រះរាជាណាចក្រកម្ពុជា ក្នុងនោះមានសមាជិកជាប្រតិបត្តិករផ្គត់ផ្គត់ទឹកស្អាតចំនួន ២៩០ស្ថានីយ និងសមាជិកជាក្រុមហ៊ុនផ្គត់ផ្គង់លើវិស័យទឹកស្អាតចំនួន ៣៤ក្រុមហ៊ុន។

## ២ .ក្រុមប្រឹក្សាភិបាល

នៅក្នុងត្រីមាសទី១ សមាគមបានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលចំនួន ២លើកដូចខាងក្រោម៖

➢ លើកទី១៖ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ វេលាម៉ោង ៩:០០ព្រឹក សមាគមបានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលសម្រាប់ត្រីមាសទី៤ ឆ្នាំ២០២២ នៅការិយាល័យសមាគម។ កិច្ចប្រជុំនេះមានការលើកឡើងពីរបាយការណ៍រីកចម្រើន និងរបាយការណ៍ហិរញ្ញវត្ថុ ប្រចាំត្រីមាសទី៤ ឆ្នាំ២០២២ និងផែនការសកម្មភាព និងផែនការថវិកា សម្រាប់ត្រីមាសទី១ ឆ្នាំ២០២៣ ។ ក្រុមប្រឹក្សាភិបាលបានស្នើឱ្យក្រុមហ៊ុនលក់សម្ភារៈតេស្តទឹកប្រចាំថ្ងៃជួយធ្វើតារាងតម្លៃដើម្បីផ្សព្វផ្សាយជូនសមាជិកឱ្យពួកគាត់ងាយ

ស្រួលក្នុងការជ្រើសរើសឧបករណ៍តេស្តទឹកស្អាតយកមកប្រើប្រាស់(ប្រាំប៉ារ៉ាម៉ែត្រ)។ ក្នុងនោះដែរអង្គប្រជុំបានសម្រេចសមាគមរៀបចំវគ្គបណ្តុះបណ្តាលបន្ថែមស្តីពីការគ្រប់គ្រងអាជីវកម្ម បច្ចេកទេស(ការធ្វើតេស្តគុណភាពទឹក ការធ្វើជ្យាតេស្ត ការសន្សំសំចៃថាមពលអគ្គិសនី ប្រតិបត្តិការ និងការថែទាំ ការគ្រប់គ្រងទឹកបាត់បង់) និងពន្ធដារ។ ដោយឡែកទាក់ទងទៅនឹងសមាជិកភាព ក្រុមប្រឹក្សាភិបាលបានសម្រេចដកសមាជិកភាពរបស់ស្ថានីយទឹកស្អាតហាន់ជ័យ ស្ថានីយទឹកស្អាតអ៊ីវជារីត និងស្ថានីយទឹកស្អាតហេងលក្ស្មីពីសមាជិកសមាគមដោយសារពួកគាត់មិនព្រមបង់សមាជិកភាព និងសុំឈប់។

- ➢ កិច្ចប្រជុំក៏បានពិភាក្សាពីការរបៀបវារៈ និងការរៀបចំរៀបសន្និបាតលើកទី១១ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៣ នៅសណ្ឋាគារហ៊ីម៉ាវ៉ារីភ្នំពេញ។
- ➢ ក្រុមប្រឹក្សាភិបាលបានឯកភាពថា សមាគមនឹងចុះអនុស្សារណៈយោគយល់គ្នាជាមួយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CWA & CMA)។

- លើកទី២៖ ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣ កិច្ចប្រជុំវិសាមញ្ញតាមប្រព័ន្ធអនឡាញ អង្គប្រជុំបានសម្រេចឱ្យក្រុមប្រឹក្សាភិបាលចូលរួមតាមការអញ្ជើញរបស់ក្រសួងឧ.វ.ប.ន ស្តីពី«ទិវាជាតិ វិទ្យាសាស្ត្រ និងនវានុវត្តន៍» និង «ពិព័រណ៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជា អន្តរជាតិ លើកទី១ ២០២៣» នៅមជ្ឈមណ្ឌលសន្និសីទ និងពិព័រណ៍កោះពេជ្រ ព្រមទាំងអញ្ជើញសមាជិកក្នុងការចូលរួម។ កិច្ចប្រជុំក៏បានពិភាក្សាពីបញ្ហារបស់ **លោក ខិញ តៃវ៉េង** ដែលខាងក្រសួងឧវបន បានចេញលិខិតឱ្យសិក្សាថ្លៃដើមឡើងវិញតាមការស្នើសុំបដិសេធលើថ្លៃលក់ទឹកដែលកំណត់ដោយគណៈកម្មាធិការវាយតម្លៃរបស់ក្រសួងឧវបន ដោយឱ្យសមាគមអញ្ជើញ **លោក ខិញ តៃវ៉េង** មកការិយាល័យសមាគម ដើម្បីពិភាក្សាលម្អិត និងស្វែងរកដំណោះស្រាយ។

## ៣. ការងារស្នូលសមាគម

### ៣.១. សន្និបាតសមាគម

សន្និបាតសមាគមលើកទី១១ ប្រចាំឆ្នាំ២០២២ បានប្រារព្ធឡើងនៅថ្ងៃទី១៧ ខែកុម្ភៈ ឆាំ២០២៣ នៅសណ្ឋាគារហ៊ីម៉ាវ៉ារី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អ៊ុំ សុថា** រដ្ឋលេខាធិការ ក្រសួង ឧវបន និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង ឧវបន។ អង្គសន្និបាតមានការចូលរួមពីក្រសួងឧវបន ក្រសួងអភិវឌ្ឍន៍ជនបទ ស្ថានទូតចក្រភពអង់គ្លេស ដៃគូអភិវឌ្ឍន៍ ក្រុមហ៊ុន និងសមាជិកសមាគម សរុប ៣០៦នាក់។

សមាគមសូមថ្លែងអំណរគុណដល់ក្រុមហ៊ុនទាំងអស់ដែលបានសហការឧបត្ថម្ភដល់សន្និបាតលើកទី ១១ នេះរួមមាន៖ ១. ក្រុមហ៊ុន E-Water ២. ក្រុមហ៊ុន TEM Trading Co., Ltd ៣. ក្រុមហ៊ុន ខេស៊ីអអាយ អ៊ិនធើណេសិនណល ខូអបភើរេសិន ឯ.ក ៤. ក្រុមហ៊ុន វ៉ាធើរ ផាតនើរ (ខេមបូឌា) ឯ.ក ៥. ក្រុមហ៊ុន វ៉ាជើម៉ិច ថេកណូឡជី ៦. ក្រុមហ៊ុន TCU Poly Enterprise ៧. ក្រុមហ៊ុន Petram Design Co., Ltd ៨. ក្រុមហ៊ុន Rose Plastic Cambodia ៩. ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា ១០. ក្រុមហ៊ុន ជីនីម៉ិច ខូអេលជីឌី ១១.

ក្រុមហ៊ុន ភ្នំពេញ ប្លាស្ទិច ប្រូដាក់ ១២. Chamroeun Microfinance Plc. ១៣. ធនាគារ BIDC Cambodia ១៤. ក្រុមហ៊ុន ISEA។




*រូបភាពទី ១ ឯកឧត្តម អ៊ុំ សុថា រដ្ឋលេខាធិកាក្រសួង ឧរបន ថ្លែងសុន្ទរកថាបើកកម្មវិធីនៃអង្គសន្និបាតលើកទី១១*



*រូបភាពទី ២ លោក លឹម មិញ នាយកប្រតិបត្តិសមាគម ធ្វើបទបង្ហាញលទ្ធផលការងារ២០២២ លើកទិសដៅការងារ២០២៣*

## ៣.២ ការចុះអនុស្សរណៈនៃការយោគយល់គ្នា

ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៣ ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា(CWA) និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា(CMA) ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការក្នុងការគាំទ្រដល់សមាជិកដែលជាអាជីវករផ្គត់ផ្គង់ទឹកស្អាត ទទួលបានលទ្ធភាពខ្ពស់ក្នុងការទទួលបានហិរញ្ញប្បទាន ពីស្ថាប័នហិរញ្ញវត្ថុ ក្នុងការពង្រីកទុកវិនិយោគលើវិស័យទឹកស្អាត ដើម្បីបង្កើនលទ្ធភាពទទួលបានទឹកស្អាតប្រើប្រាស់នៅប្រទេសកម្ពុជា។



*រូបភាពទី ៣ ពិធីចុះអនុស្សរណៈយោគគ្នារវាង CWA និង CMA (លោក ឡេង ខៀវ ខាងឆ្វេង)*

## ៣.៣. ការសម្របសម្រួលសមាជិក

នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣ សមាគមបានសហការជាមួយអគ្គនាយកដ្ឋានទឹកស្អាតនៃក្រសួងឧវបន ដែលដឹកនាំសម្របសម្រួលពី **លោក ហ៊ុយ រិទ្ធី** អគ្គនាយករងទឹកស្អាត អមដោយមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានទឹកស្អាត និង**លោក សំរិទ្ធ វណ្ណៈ និងលោក សារ៉ា រតនៈ** អនុប្រធានការិយាល័យទឹកស្អាត នៃមន្ទីរឧ.វ.ប.ន ខេត្តពោធិ៍សាត់ បានរៀបចំកិច្ចប្រជុំសម្របសម្រួលការផ្គត់ផ្គង់ទឹកស្អាតនៅក្រៅតំបន់អាជ្ញាបណ្ណ។ ហើយកិច្ចប្រជុំនេះធ្វើឡើងនៅសាលាឃុំរំលេច ដោយមានការចូលរួមពីសមាគមដឹកនាំដោយ **លោក ឡេង ខៀវ** ប្រធានក្រុមប្រឹក្សាភិបាល និងតំណាងប្រតិបត្តិកររួមមានៈ **លោក សុត សឿន** ម្ចាស់ស្ថានីយទឹកស្អាតសុតសឿន និង **លោក តី សច្ចៈរិទ្ធ** តំណាងស្ថានីយទឹកស្អាតវ៉េងវីរៈ លោកមេឃុំរំលេច ក្រុមប្រឹក្សាឃុំរំលេច និងប្រធានភូមិនៅក្នុងឃុំរំលេច ស្រុកបាកាន ខេត្តពោធិ៍សាត់។ ក្រោយពីការពិភាក្សា និងការសម្របសម្រួលមក ភាគីទាំងពីរនៅមិនឯកភាពគ្នា ហើយភាគីម្ខាងៗបានស្នើសុំដូចខាងក្រោមៈ

- **លោក ស៊ុត សឿន** ស្នើសុំយក ៨ភូមិ ក្នុងឃុំរំលេច *(នៅជាប់តំបន់អាជ្ញាបណ្ណរបស់ខ្លួន)* ដែលខ្លួនបាននឹងកំពុងផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋ។
- **លោក តី សច្ចៈរិទ្ធ** ប្រកាន់ជំហរមិនឱ្យ ៨ភូមិ ក្នុងឃុំរំលេច *(នៅក្នុងតំបន់អាជ្ញាបណ្ណដែលខ្លួនកំពុងរង់ចាំការសម្រេចពីក្រសួងឧវបន)* តាមការស្នើសុំរបស់ **លោក ស៊ុត សឿន** នោះទេ ហើយបានសន្យាថា នឹងផ្គត់ផ្គង់ទឹកស្អាតមកក្នុងឃុំរំលេចក្នុងរយៈពេលតែ ៣ខែ ដោយសំអាងថា បានធ្វើអាងប្រព្រឹត្តិកម្មរួចរាល់ស្ទើរតែទាំងស្រុង( *តែចម្ងាយពីអាងប្រព្រឹត្តិកម្មមក*

*ឃុំរំលេចមានចម្ងាយ ៣២គីឡូម៉ែត្រ)*។ ក្រុមការងារនឹងធ្វើកំណត់ហេតុនៃការប្រជុំនេះទៅថ្នាក់ដឹកនាំក្រសួងដើម្បីពិនិត្យ និងសម្រេច។



*រូបភាពទី ៤ កិច្ចប្រជុំដោះស្រាយទំនាស់រវាងលោក សុត សឿន និងលោក វេង វីរៈ*

ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ សមាគមបានសហការជាមួយអគ្គនាយកដ្ឋានទឹកស្អាតនៃក្រសួងឧវបន ដែលដឹកនាំសម្របសម្រួលពី **លោក ហ៊ុយ រិទ្ធី** អគ្គនាយករងទឹកស្អាត អមដោយមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានទឹកស្អាត និង**លោក រស់ វិសិទ្ធ** អនុប្រធានមន្ទីរឧវបន ខេត្តបាត់ដំបង និងសហការី បានរៀបចំកិច្ចប្រជុំសម្របសម្រួលការផ្គត់ផ្គង់ទឹកស្អាតនៅក្រៅតំបន់អាជ្ញាប័ណ្ណ។ កិច្ចប្រជុំនេះធ្វើឡើងនៅសាលាឃុំឈើទាល ដោយមានការចូលរួមពីសមាគមដឹកនាំដោយ **លោក ឡេង ខៀវ** ប្រធានក្រុមប្រឹក្សាភិបាល និងតំណាងប្រតិបត្តិកររួមមាន៖ **លោក ខោ ប៊ុនហ៊ាត** ម្ចាស់ស្ថានីយទឹកស្អាតខោប៊ុនហ៊ាត និង**លោក តាក់ ចាន់គយ** ម្ចាស់ស្ថានីយទឹកស្អាតបាយដំរាំ លោកអភិបាលរងស្រុកបាណន់ ក្រុមប្រឹក្សាឃុំឈើទាល និងប្រធានភូមិ ។


*រូបភាពទី ៥ កិច្ចប្រជុំសម្របសម្រួល (ស្ថានីយទឹកស្អាត ហ្គ្រីនហ្សូន និង ស្ថានីយទឹកស្អាត តូវ នារីផល*

ភាគីទាំងពីរឯកភាពគ្នា ដោយស្ថានីយទឹកស្អាតបាយដំរាំបានព្រមព្រៀងប្រគល់អតិថិជនដែលនៅក្នុងតំបន់អាជ្ញាបណ្ណរបស់ **លោក ខោ ប៊ុនហ៊ាត** ជូនទៅស្ថានីយទឹកស្អាតខោប៊ុនហ៊ាត ហើយស្ថានីយទឹកស្អាតខោប៊ុនហ៊ាត មិនយកថ្លៃភ្ជាប់តំណទឹកស្អាតអតិថិជនទាំង ១៦គ្រួសារនោះទេ។

ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣សមាគម សហការជាមួយអគ្គនាយកដ្ឋានទឹកស្អាតនៃក្រសួងឧស្សាហកម្ម... ឧវបន ដែលដឹកនាំសម្របសម្រួលពី **លោក ហ៊ុយ រិទ្ធី** អគ្គនាយករងទឹកស្អាត អមដោយមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានទឹកស្អាត និងលោក **អ៊ិម ណុយ** អនុប្រធានមន្ទីរឧវបន ខេត្តបន្ទាយមានជ័យ និងសហការី បានរៀបចំកិច្ចប្រជុំសម្របសម្រួលការផ្គត់ផ្គង់ទឹកស្អាតក្រៅតំបន់អាជ្ញាបណ្ណ។ កិច្ចប្រជុំធ្វើឡើងនៅសាលាឃុំបន្ទាយនាង ដោយមានការចូលរួមពីសមាគមដឹកនាំដោយ **លោក ឡេង ខៀវ** ប្រធានក្រុមប្រឹក្សាភិបាល និងតំណាងប្រតិបត្តិកររួមមាន៖ **លោក ទិត ហេងណារ៉ា** តំណាងម្ចាស់ស្ថានីយទឹកស្អាតភាពថាច និង **លោក ង៉ូ សុផារិទ្ធ** តំណាងម្ចាស់ស្ថានីយទឹកស្អាតតូវនារីផល និងលោកមេឃុំបន្ទាយនាង។ ភាគីទាំងពីរបានឯកភាពដោយឱ្យស្ថានីយទឹកស្អាតភាពថាច បន្តផ្គត់ផ្គង់ទឹកស្អាតជូនអតិថិជនចំនួន ៣ ស្ថិតនៅក្នុងដែនអាជ្ញាបណ្ណរបស់ប្រតិបត្តិករតូវនារីផល រួមមាន៖ ប៉ុស្តិ៍ប៉ូលីសបន្ទាយនាង មណ្ឌលសុខភាពបន្ទាយនាង និងផ្ទះមួយរបស់សមាជិកគ្រួសាររបស់ លោក ភាពថាច។ ប្រតិបត្តិករភាពថាច ត្រូវឈប់បន្តការភ្ជាប់បណ្តាញឱ្យទៅអតិថិជនក្រៅពី៣គ្រួសារខាងលើ។ ប្រសិនបើមានការភ្ជាប់ឱ្យទៅអតិថិជនថ្មីដោយអចេតនាណាមួយ ប្រតិបត្តិករតូវនារីផល ត្រូវផ្តល់ជាដំណឹងនោះទៅប្រតិបត្តិករភាពថាច ហើយប្រតិបត្តិករភាពថាច ត្រូវកាត់ចេញជាបន្ទាន់។




*រូបភាពទី ៦ កិច្ចប្រជុំសម្របសម្រួល (ស្ថានីយទឹកស្អាត ខោ ប៊ុនហ៊ាត និង ស្ថានីយទឹកស្អាត បាយដំរាំ)*

## ៣.៤. វគ្គបណ្តុះបណ្តាល

ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា បានសហការជាមួយមន្ទីរឧវបន និងសាខាពន្ធដារខេត្តបាត់ដំបង បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី«សិទ្ធិ និងកាតព្វកិច្ច

របស់អ្នកជាប់ពន្ធ និងនីតិវិធីនៃការបង់ពន្ធរបស់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត» នៅសណ្ឋាគារភ្លាស់ស៊ី ខេត្តបាត់ដំបង ដែលមានអ្នកចូលរួមសរុបចំនួន ២៨នាក់ (ស្រី ១១នាក់) ដែលក្នុងនោះមានការអញ្ជើញចូលរួមពី លោកអនុប្រធានមន្ទីរឧវបន ខេត្តបាត់ដំបង និងប្រធានការិយាល័យទឹកស្អាត លោកអនុប្រធានសាខាពន្ធដារ ខេត្តបាត់ដំបង និងមន្ត្រីជំនាញ ប្រតិបត្តិករចំនួន ២១នាក់ (មកពី ១៥ស្ថានីយ (មកពីខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តពោធិ៍សាត់ និងខេត្តកំពង់ស្ពឺ) និងរដ្ឋាករទឹកសាធារណៈខេត្តបាត់ដំបង។

គោលបំណង៖ ក្រោយពីបញ្ចប់វគ្គសិក្ខាកាមអាចមានលទ្ធភាព៖

១. រៀបរាប់បានអំពីនីតិវិធីក្នុងការចុះបញ្ជីពន្ធដារបស់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត
២. រៀបរាប់បានពីរបៀបរបបនៃការបង់ពន្ធរបស់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត
៣. រៀបរាប់បានអំពីកាតព្វកិច្ច និងសិទ្ធិរបស់អ្នកជាប់ពន្ធ។



*រូបភាពទី ៧ ការថ្លែងសុន្ទរកថាបើកកម្មវិធីបណ្តុះបណ្តាល*

## ៤. ការងារគម្រោង

### ៤.១. គម្រោងពង្រឹងគណនេយ្យភាពរបស់សេវាករផ្គត់ផ្គង់ទឹកស្អាត ដើម្បីលើកកម្ពស់សេវាកម្មទឹកស្អាត នៅក្នុងខេត្តកណ្តាល ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង( WaterAid )

#### ៤.១.១ ការឧបត្ថម្ភធនលើការភ្ជាប់បណ្តាញទឹកស្អាតជូនគ្រួសារក្រីក្រ

ក្នុងត្រីមាសនេះ ស្ថានីយទឹកស្អាតចំនួន៥ស្ថានីយ រួមមាន៖ ១). ស្ថានីយផ្គត់ផ្គង់ទឹកស្អាតក្ដុល ២). ស្ថានីយផ្គត់ផ្គង់ទឹកស្អាតសាលាលេខ៥ ៣).ស្ថានីយផ្គត់ផ្គង់ទឹកស្អាតហេងអៀម ៤). ស្ថានីយផ្គត់ផ្គង់ទឹកស្អាតពាម និង ៥). ស្ថានីយផ្គត់ផ្គង់ទឹកស្អាតអំពិលទឹក បានភ្ជាប់សេវាទឹកស្អាតជូនគ្រួសារក្រីក្របានចំនួន ៤៧គ្រួសារ។

## ៤.១.២ ការប្រមូលទិន្នន័យចុងគ្រា

បុគ្គលិកគម្រោងបានសហការជាមួយរដ្ឋបាលស្រុកចំនួន ៦ (១.ស្រុកសាមគ្គីមានជ័យ ២. ស្រុកកំពង់ត្រឡាច ៣. ស្រុកសំរោងទង ៤. ស្រុកថ្ពង ៥. ស្រុកអង្គស្នួល ៦). ស្រុកកណ្តាលស្ទឹង) និងមន្ទីរឧវបនខេត្តកំពង់ស្ពឺ ចុះប្រមូលទិន្នន័យចុងគ្រា។ ជាលទ្ធផលក្រុមការងារបានប្រមូលទិន្នន័យពីអាជ្ញារមូលដ្ឋានចំនួន ៣៥ឃុំ និងសហគមន៍ចំនួន ៣៥ភូមិ (ក្នុងឃុំទាំង៣៥) ដែលមានអ្នកចូលរួមសរុបចំនួន ៧៩៣នាក់ (ស្រី៣៨១)។



*រូបភាពទី ៩ ការប្រមូលទិនន័យចុងគ្រានៅស្រុកសាមគ្គីមានជ័យ និងស្រុលកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង*



*រូបភាពទី ៨ ការប្រមូលទិនន័យចុងគ្រានៅស្រុកអង្គស្នួល និងស្រុលកណ្តាលស្ទឹង ខេត្តកណ្តាល*



*រូបភាពទី១០ ការប្រមូលទិនន័យចុងគ្រានៅស្រុកថ្ពង និងស្រុលសំរោងទង ខេត្តកំពង់ស្ពឺ*

### ៤.២ គម្រោងបង្កើនការទទួលសេវាទឹកស្អាត និងអនាម័យដែលធន់នឹងអាកាសធាតុសម្រាប់ជនងាយរងគ្រោះនៅតាមសហគមន៍ និងភាពជាអ្នកដឹកនាំរបស់ស្ត្រីផ្ដើមក្នុងវិស័យទឹកស្អាត និងអនាម័យប្រកបដោយបរិយាបន្ន

**៤.២.១ កិច្ចប្រជុំផ្សព្វផ្សាយ ៖** ត្រីមាសទី១ គម្រោងបានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយចំនួន ៤លើក៖

- លើកទី១៖ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៣ កិច្ចប្រជុំផ្សព្វផ្សាយសហគមន៍ស្តីពី «សេវាផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ និងទស្សនកិច្ចសិក្សាប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត» នៅស្ថានីយផ្គត់ផ្គង់ទឹកស្អាត ឡេង ខៀវ ព្រែកអំបិល ស្ថិតនៅភូមិព្រែកតាឡៃ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្ដាល។

  កិច្ចប្រជុំមានអ្នកចូលរួមសរុបចំនួន ២៩នាក់ ស្រី១៦នាក់ ដែលអញ្ជើញចូលរួមពីអាជ្ញាធរឃុំ ក្រុមប្រឹក្សាឃុំ តំណាងអង្គការវ៉េតជីអេត លោកគ្រូបង្រៀន សិស្សានុសិស្ស តំណាងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ប្រជាពលរដ្ឋ និងបុគ្គលិកសមាគម។



*រូបភាពទី ១១ កិច្ចប្រជុំផ្សព្វផ្សាយ ដោយកញ្ញា ខាត់ ដាវី នៅស្ថានីយទឹកស្អាត ឡេង ខៀវ*

- លើកទី២៖ ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៣ កិច្ចប្រជុំផ្សព្វផ្សាយសហគមន៍ស្តីពី សេវាផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ និងទស្សនកិច្ចសិក្សាប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត» នៅស្ថានីយផ្គត់ផ្គង់ទឹកស្អាត ស្វាយប្រទាល ស្ថិតនៅភូមិព្រែកតាតិន ឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្ដាល។

  កិច្ចប្រជុំនេះដែលមានសមាសភាពអ្នកចូលរួមសរុបចំនួន២៦ នាក់ស្រី១៣ នាក់ អញ្ជើញចូលរួមពីអាជ្ញាធរឃុំ ក្រុមប្រឹក្សាឃុំ មេឃុំ លោកគ្រូបង្រៀន តំណាងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត តំណាំងជនពិការ មានប្រជាពលរដ្ឋ និងបុគ្គលិកសមាគម។

  ក្រោយកិច្ចប្រជុំសិក្ខាកាមអ្នកចូលរួមអាចមានលទ្ធភាព៖១).ពន្យល់ពីសារៈសំខាន់នៃការប្រើប្រាស់ទឹកស្អាតតាមបំពង់ និងការទុកដាក់ទឹកអោយមានសុវត្ថិភាព ២).លើកទឹកចិត្តដល់ប្រជាពលរដ្ឋក្នុងសហគមន៍ ជាពិសេសគ្រួសារក្រីក្រឱ្យភ្ជាប់បណ្ដាញទឹកស្អាត ៣).លើកទឹកចិត្តដល់អ្នកចូលរួមជួយផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងសហគមន៍បន្ត។



*រូបភាពទី ១២ លោក ហ៊ាង ដារ៉ា ម្ចាស់ស្ថានីយទឹកស្អាត ស្វាយប្រទាល ប្រជុំផ្សព្វផ្សាយគម្រោង*

- លើកទី៣៖ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៣ កិច្ចប្រជុំផ្សព្វផ្សាយសហគមន៍ស្តីពី សេវាផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ និងទស្សនកិច្ចសិក្សាប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត នៅស្ថានីយផ្គត់ផ្គង់ទឹកស្អាតត្រើយស្លា ស្ថិតនៅភូមិព្រែកបាឡាត់ធឹង ឃុំត្រើយស្លា ស្រុកស្អាង ខេត្តកណ្តាល។

  កិច្ចប្រជុំនេះដែលមានសមាសភាពអ្នកចូលរួមសរុបចំនួន២៣ នាក់ស្រី៥ នាក់ អញ្ជើញចូលរួមពីអាជ្ញាធរឃុំ ក្រុមប្រឹក្សាឃុំ មេឃុំ តំណាងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ប្រជាពលរដ្ឋ និងបុគ្គលិកសមាគម។

  ក្រោយកិច្ចប្រជុំសិក្ខាកាមអ្នកចូលរួមអាចមានលទ្ធភាព៖ ១). ពន្យល់ពីសារៈសំខាន់នៃការប្រើប្រាស់ទឹកស្អាតតាមបំពង់ និងការទុកដាក់ទឹកអោយមានសុវត្ថិភាព ២). លើកទឹកចិត្តដល់ប្រជាពលរដ្ឋក្នុងសហគមន៍ ជាពិសេសគ្រួសារក្រីក្រឱ្យភ្ជាប់បណ្តាញទឹកស្អាត ៣). លើកទឹកចិត្តដល់អ្នកចូលរួមជួយផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងសហគមន៍បន្ត។



*រូបភាពទី ១៣ លោក ខិញ តៃវ៉េង ម្ចាស់ស្ថានីយទឹកស្អាត ត្រើយស្លា ប្រជុំផ្សព្វផ្សាយគម្រោង*

- លើកទី៤៖ ថ្ងៃទី០២ ខែមីនា ឆ្នាំ២០២៣ កិច្ចប្រជុំផ្សព្វផ្សាយសហគមន៍ស្តីពី សេវាផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ និងទស្សនកិច្ចសិក្សាប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត នៅស្ថានីយផ្គត់ផ្គង់ទឹកស្អាតកោះខ្សាច់ទន្លា ស្ថិតនៅភូមិក្បាលកោះកើត ឃុំកោះខ្សាច់ទន្លា ស្រុកស្អាង ខេត្តកណ្តាល។

កិច្ចប្រជុំនេះដែលមានសមាសភាពអ្នកចូលរួមសរុបចំនួន៣៥ នាក់ស្រី២១ នាក់ អញ្ជើញចូលរួមពីអាជ្ញាធរឃុំ ក្រុមប្រឹក្សាឃុំ មេឃុំ តំណាងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ប្រជាពលរដ្ឋ និងបុគ្គលិកសមាគម។

ក្រោយកិច្ចប្រជុំសិក្ខាកាមអ្នកចូលរួមអាចមានលទ្ធភាព៖ ១). ពន្យល់ពីសារៈសំខាន់នៃការប្រើប្រាស់ទឹកស្អាតតាមបំពង់ និងការទុកដាក់ទឹកអោយមានសុវត្ថិភាព ២). លើកទឹកចិត្តដល់ប្រជាពលរដ្ឋក្នុងសហគមន៍ ជាពិសេសគ្រួសារក្រីក្រឱ្យភ្ជាប់បណ្តាញទឹកស្អាត ៣). លើកទឹកចិត្តដល់អ្នកចូលរួមជួយផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងសហគមន៍បន្ត។



*រូបភាពទី ១៤ ប្រជុំផ្សព្វផ្សាយគម្រោង ស្ថានីយទឹកស្អាត ឃុំកោះខ្សាច់ទន្លា*

### ៤.២.២ ការគាំទ្រដល់ការឧបត្ថម្ភធនលើការភ្ជាប់ទឹកស្អាតជូនគ្រួសារក្រីក្រ

គិតត្រឹមចុងត្រីមាសទី១នេះ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនចំនួនពីរ (២) បានទទួល និងយល់ព្រមគាំទ្រដល់ការឧបត្ថម្ភធនលើការភ្ជាប់ទឹកស្អាតជូនគ្រួសារក្រីក្រ។ ជាលទ្ធផល គ្រួសារក្រីក្រចំនួន ៤០គ្រួសារ ដែលមានសមាជិកចំនួនប្រមាណ១៧១នាក់ បានភ្ជាប់សេវាទឹកស្អាតពីស្ថានីយទាំង២នេះ។



*រូបភាពទី ១៥ ការតភ្ជាប់ទឹកស្អាតរបស់សហគមន៍*

## ៤.៣ គម្រោងការពង្រឹងមូលដ្ឋានគ្រឹះសម្រាប់សន្តិសុខទឹក នៅកម្រិតស្រុក ក្នុងប្រទេសកម្ពុជា (WaterAid)

### ៤.៣.១. កិច្ចប្រជុំរវាងអាជ្ញាធរមូលដ្ឋាន និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត

នៅក្នុងត្រីមាសទី១ គម្រោងបានរៀបចំកិច្ចប្រជុំរវាងអាជ្ញាធរមូលដ្ឋាន និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ចំនួន ៤ប្រជុំដូចខាងក្រោម៖

- លើកទី១៖ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣ កិច្ចប្រជុំប្រចាំឆ្នាំរវាងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត និងអាជ្ញាធរមូលដ្ឋាន ចំនួនពីរស្ថានីយ នៅស្ថានីយផ្គត់ផ្គង់ទឹកស្អាតហេងអៀម និងស្ថានីយផ្គត់ផ្គង់ទឹកស្អាតត្បែងខ្ពស់។

  ១. ស្ថានីយផ្គត់ផ្គង់ទឹកស្អាតហេងអៀម ធ្វើនៅសាលាឃុំស្វាយ ស្ថិតនៅភូមិត្រពាំងថ្ម ឃុំស្វាយ ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ដែលមានអ្នកចូលរួមសរុប ២៣នាក់ ស្រី៤នាក់។

  ២. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ត្បែងខ្ពស់ ធ្វើនៅសាលាឃុំសេដ្ឋី ស្ថិតនៅភូមិរ៉ា ឃុំត្បែងខ្ពស់ ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំ ដែលមានអ្នកចូលរួមសរុប ១៥នាក់ ស្រី៧នាក់។




*រូបភាពទី ១៦ កិច្ចប្រជុំរវាងអាជ្ញាធរមូលដ្ឋាន និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត នៅឃុំស្វាយ*

❖ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣ នៅស្ថានីយផ្គត់ផ្គង់ទឹកស្អាត ឃុំពាម និងស្ថានីយផ្គត់ផ្គង់ទឹកស្អាត មករា ស្វាយជុក។

១. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ឃុំពាម ធ្វើនៅសាលាឃុំពាម ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ដែលមានអ្នកចូលរួមសរុប២០នាក់ ស្រី៨នាក់។

២. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត មករា ស្វាយជុក ធ្វើនៅសាលាឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំ ដែលមានអ្នកចូលរួមសរុប១៣នាក់ ស្រី៤នាក់។




*រូបភាពទី ១៧ កិច្ចប្រជុំរវាងអាជ្ញាធរមូលដ្ឋាន និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត នៅឃុំពាម*

### ៤.៣.២. ប្រជុំឆ្លុះបញ្ចាំងលទ្ធផលនៃការអនុវត្តន៍គណនេយ្យភាព វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ

បុគ្គលិកគម្រោងបានចូលរួមក្នុងកិច្ចប្រជុំប្រជុំឆ្លុះបញ្ចាំងលទ្ធផលនៃការអនុវត្តន៍គណនេយ្យភាព វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ ២០២៣ នៅសាលប្រជុំរបស់សាលាស្រុកសាមគ្គីមានជ័យ។ កិច្ចប្រជុំនេះសហការរៀបចំដោយអង្គការតែជីអេតមន្ទីរឧវបេន និងមន្ទីរអភិវឌ្ឍន៍ជនបទ សមាគម និងរដ្ឋបាលស្រុកសាមគ្គីមានជ័យ។ កិច្ចប្រជុំមានគោលបំណងចំនួន ៣ ដូចខាងក្រោម៖

១. លើកកម្ពស់ការផ្តល់សេវាសាធារណៈ វិស័យទឹកស្អាតដល់កម្រិតគុណភាពក្នុងសហគមន៍
២. ឆ្លុះបញ្ចាំងគ្នាពីតួនាទី ភារៈកិច្ចទំនួលខុសត្រូវរបស់អ្នកទទួលសេវា និងអ្នកផ្តល់សេវាទឹកស្អាត
៣. បង្កើនអោយមានការប្រកួតប្រជែង ចំពោះអ្នកផ្គត់ផ្គង់ទឹក ដើម្បីបង្កើនសេវាផ្គត់ផ្គង់ទឹកឱ្យកាន់តែមានប្រសិទ្ធិភាពទូទាំងស្រុកសាមគ្គីមានជ័យ។

ជាលទ្ធផលនៃកិច្ចប្រជុំបានបង្ហាញថា ស្ថានីយផ្គត់ផ្គង់ទឹកស្អាតចំនួន ៣ស្ថានីយទទួលបានពានរង្វាន់ជាប្រតិបត្តិករឆ្នើមប្រចាំស្រុកសាមគ្គីមានជ័យ ដែលមានរាយឈ្មោះដូចខាងក្រោម៖

១. ស្ថានីយផ្គត់ផ្គង់ទឹកស្អាតត្បែងខ្ពស់ ទទួលបានចំណាត់ថ្នាក់លេខ ១ ជាប្រតិបត្តិករឆ្នើម ព្រមទាំងទទួលបាននាឡិកាទឹកចំនួន ៣០ ជារង្វាន់លើកទឹកចិត្តក្នុងការផ្តល់សេវាផ្គត់ទឹកស្អាតបានល្អប្រសើរ។
២. ក្រុមហ៊ុនលង្វែកឌីវេឡុបម៉ិនវ៉តធើរសឹបផ្លាយ ឯ.ក ទទួលបានចំណាត់ថ្នាក់លេខ ២ ជាប្រតិបត្តិករឆ្នើម ព្រមទាំងទទួលបាននាឡិកាទឹកចំនួន ២៥ ជារង្វាន់លើកទឹកចិត្តក្នុងការផ្តល់សេវាផ្គត់ទឹកស្អាតបានល្អប្រសើរ។
៣. ស្ថានីយផ្គត់ផ្គង់ទឹកស្អាតហេងអៀម ទទួលបានចំណាត់ថ្នាក់លេខ ៣ ជាប្រតិបត្តិករឆ្នើម ព្រមទាំងទទួលបាននាឡិកាទឹកចំនួន ២០ ជារង្វាន់លើកទឹកចិត្តក្នុងការផ្តល់សេវាផ្គត់ទឹកស្អាតបានល្អប្រសើរ។

ក្នុងនោះដែរជាការលើកទឹកចិត្តជូនប្រតបត្តិករដែលពុំបានទទួលចំណាត់ថ្នាក់ គម្រោងបានផ្តល់ជូននាឡិកាទឹកចំនួន ១០ (ក្នុង១ស្ថានីយ) ជូនស្ថានីយចំនួន៣ ទៀតផងដែរ។




*រូបភាពទី ១៨ ការផ្តល់រង្វាន់ដល់ប្រតិបត្តិករឆ្នើមប្រចាំស្រុកសាមគ្គីមានជ័យ*

## ៤.៤ គម្រោងសិក្សារៀបចំព័ត៌មានប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត សម្រាប់រកទុនកម្ចី- **Water.org**

### ៤.៤.១. វគ្គបណ្តុះបណ្តាល

- ថ្ងៃទី៥-៦ ខែមករា ឆ្នាំ២០២៣ សហការជាមួយក្រុមហ៊ុន E-Water រៀបចំវគ្គបណ្តុះបណ្តាលស្តីពី«ការបញ្ចូលទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត» ក្រោមជំនួយឧបត្ថម្ភពីអង្គការ Water.Org នៅការិយាល័យរបស់សមាគម។ វគ្គបណ្តុះបណ្តាលមានគោលបំណងឱ្យអ្នកចូលរួមអាចៈ

  ១. ពិនិត្យទិន្នន័យអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដែលបានបញ្ជូនមកកាន់សមាគម
  ២. ស្វែងយល់អំពីរបៀបបញ្ចូលទិន្នន័យអាជីវកម្មចូលក្នុងប្រព័ន្ធ DMS
  ៣. រៀបចំរបាយការណ៍ហិរញ្ញវត្ថុចេញពីប្រព័ន្ធ DMS។

វគ្គបណ្តុះបណ្តាលនេះមានអ្នកចូលរួមសរុបចំនួន១៩ នាក់ស្រី៧ នាក់ មានការអញ្ជើញចូលរួមពីប្រតិបត្តិករចំនួន១៣ នាក់ មកពី១១ ស្ថានីយ។



*រូបភាពទី ១៩ វគ្គបណ្តុះបណ្តាលស្តីពី «ការបញ្ចូលទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត*

## ៤.៥ ការកែលម្អលទ្ធភាពទទួលបានហិរញ្ញប្បទានរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជននៅកម្ពុជា ដើម្បីពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាត (Water.org)

### ៤.៥.១. ការចុះកិច្ចព្រមព្រៀង

ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៣ សមាគម បានចុះកិច្ចព្រមព្រៀងទទួលយកគម្រោងថ្មីស្តីពី«ការកែលម្អលទ្ធភាពទទួលបានហិរញ្ញប្បទានរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជននៅកម្ពុជា ដើម្បីពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាត (Improving Cambodian Utilities' Bankability to Increase Water Access)» ជាមួយអង្គការ Water.org ។ គម្រោងនេះមានទិសដៅ«ធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានទឹកស្អាតសម្រាប់ប្រជាជនកម្ពុជាជាពិសេសប្រជាពលរដ្ឋក្រីក្រ» (Improved access to water for Cambodian living in poverty)។ លទ្ធផលរំពឹងសម្រាប់គម្រោងនេះ គឺ៖

១. ប្រតិបត្តិករយ៉ាងតិចចំនួន ៩ស្ថានីយ នឹងទទួលបានហិរញ្ញប្បទានពីស្ថាប័នហិរញ្ញវត្ថុ។
២. តំណថ្មីចំនួន ២០.០០០ នឹងកើនឡើង តាមរយៈសកម្មភាពសម្របសម្រួលរបស់គម្រោងដើម្បីឱ្យប្រជាជនមានលទ្ធភាពទទួលបានទឹកស្អាតប្រើប្រាស់។
៣. ប្រតិបត្តិករនឹងធ្វើឱ្យប្រសើរឡើងនូវគុណភាពទឹកស្អាតដោយអនុលោមតាមស្តង់ដារគុណភាពទឹកស្អាតថ្នាក់ជាតិ ជាពិសេសប៉ារ៉ាម៉ែត្រប្រចាំថ្ងៃទាំង៥។




*រូបភាពទី ២០ ការចុះកិច្ចព្រមព្រៀងទទួលយកគម្រោងរវាង សមាគម និងអង្គការ water.org*

## ៤.៥.២. ការសម្របសម្រួលទស្សនកិច្ចសិក្សា

ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣ សមាគមបានសម្របសម្រួលទស្សនកិច្ចសិក្សារបស់ម្ចាស់មូលនិធិនៃអង្គការ Water.org ទៅទស្សនកិច្ចនៅស្ថានីយផ្គត់ផ្គង់ទឹកស្អាតកំពង់ចំលង និងជួបជាមួយអតិថិជននៃស្ថានីយទឹកស្អាតកំពង់ចំលងចំនួន ២គ្រួសារផងដែរ។



*រូបភាពទី ២១ ទស្សនកិច្ចនៅស្ថានីយផ្គត់ផ្គង់ទឹកស្អាតកំពង់ចំលង របស់អង្គការ water.org*

## ៤.៥.៣. សិក្ខាសាលាផ្សព្វផ្សាយគម្រោង

ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣ សមាគមបានសិក្ខាសាលាផ្សព្វផ្សាយគម្រោង«ការកែលម្អលទ្ធភាពទទួលបានហិរញ្ញប្បទានរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជននៅកម្ពុជាដើម្បី

ពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាត» នៅសណ្ឋាគារសាន់វ៉េ រាជធានីភ្នំពេញ។ សិក្ខាសាលានេះមានអ្នកចូលរួមសរុបចំនួន ៥៩នាក់ ស្រី១៧នាក់ មានប្រតិបត្តិករចំនួន ៤១ នាក់ ៣៨ស្ថានីយ។



*រូបភាពទី ២២ សិក្ខាសាលាផ្សព្វផ្សាយគម្រោង*

ក្នុងថ្ងៃដដែល សមាគមបានស្នើសុំកិច្ចសហការជាមួយអគ្គនាយកដ្ឋានទឹកស្អាតនៃក្រសួងឧវបន ដើម្បីរៀបចំសិក្ខាសាលាតម្រង់ទិសស្តីពី«ប្រកាសអនុញ្ញាឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត»។ សិក្ខាសាលាតម្រង់ទិសមានគោលបំណង៖

១. ស្វែងយល់អំពីឯកសារគតិយុត្តពាក់ព័ន្ធទៅនឹងសេវាទឹកស្អាតតាមបំពង់
២. រៀបរាប់បានពីចំណុចសំខាន់ៗដែលមាននៅក្នុងប្រកាសអនុញ្ញាឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត
៣. ពិភាក្សាអំពីចំណុចដែលអនុវត្តបានល្អ និងចំណុចដែលត្រូវកែលម្អ ដើម្បីអនុវត្តប្រកាសឱ្យបានត្រឹមត្រូវ។

## ៥. គម្រោងសម្ព័ន្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព និងការគាំទ្រសំឡេងដើម្បីសមធម៌សង្គម

- ថ្ងៃទី០៧ ខែ កុម្ភៈ ឆ្នាំ២០២៣ ៖ សមាគមបានរៀបចំកិច្ចប្រជុំនៅសាលាស្រុកកំពង់សីលា ខេត្តព្រះសីហនុ ស្តីពី«ការជ្រើសរើសឃុំគោលដៅ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតសម្រាប់សហការជាមួយគម្រោងសម្ពន្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព និងការគាំទ្រសំឡេងដើម្បីសមធម៌សង្គម» នៅសាលាស្រុកកំពង់សីលា សរុបរួមអ្នកចូលរួមកិច្ចប្រជុំ ៧រូប និងស្រី ១រូប មន្ត្រីអប់រំដែលមកពីសហគមន៍បណ្តុះបណ្តាលកុមារ។
- ថ្ងៃទី០៨ ខែ កុម្ភៈ ឆ្នាំ២០២៣ ៖ សមាគមបានរៀបចំកិច្ចប្រជុំនៅសាលាស្រុកកំពង់ត្រាច ខេត្តកំពត ស្តីពី«ការជ្រើសរើសឃុំគោលដៅ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតសម្រាប់សហការជាមួយ

គម្រោងសម្ពន្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព និងការគាំទ្រសំឡេងដើម្បីសមធម៌សង្គម» នៅសាលាស្រុកកំពង់ត្រាច សរុបរួមអ្នកចូលរួមកិច្ចប្រជុំ ១៣រូប (ស្រី ៤រូប) ។



*រូបភាពទី ២៣ កិច្ចប្រជុំជ្រើសរើសឃុំគោលដៅ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត*

- ថ្ងៃទី២៤-២៤ ខែកុម្ភៈ ឆ្នាំ២០២៣ សមាគមការបានចុះសិក្សាលម្អិតលើការពង្រីកបណ្តាញបំពង់ទឹកស្អាត នៅស្រុកកំពង់សីលា ខេត្តព្រះសីហនុ និងនៅស្រុកកំពង់ត្រាច ខេត្តកំពត។ ជាលទ្ធផលបានសិក្សាចំនួន១៣ភូមិ សម្រាប់ពីរស្ថានីយ (ស្ថានីយផ្គត់ផ្គង់ទឹកស្អាតភ្នំមាស សិក្សាបានចំនួន ៨ភូមិ និងស្ថានីយផ្គត់ផ្គង់ទឹកស្អាតកំពង់សីលា សិក្សាបានចំនួន ៥ភូមិ)។



*រូបភាពទី ២៤ ការចុះសិក្សាលម្អិតពីការពង្រីកបណ្តាញបំពង់ទឹកស្អាត*

## ៦. ទស្សនកិច្ចសិក្សាក្រៅប្រទេស

សមាគមបានដឹកនាំក្រុមការងារ និងសមាជិកសរុបចំនួន ១០នាក់ រួមមាន៖ ប្រធានក្រុមប្រឹក្សាភិបាល ១នាក់ បុគ្គលិកសមាគម ៣នាក់ និងប្រតិបត្តិករដឹកនាំជាស្ត្រី ចំនួន ៦នាក់ ចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពី«ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត» នៅទីក្រុងគីតាឃ្យូហ្សុ ប្រទេសជប៉ុន ចាប់ពីថ្ងៃទី៩ ដល់១១ ខែមករា ឆ្នាំ២០២៣ ក្រោមការគាំទ្រឧបត្ថម្ភពីក្រសួងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្ម នៃរាជរដ្ឋាភិបាលជប៉ុន តាមរយៈកិច្ចសហការ និងសម្របសម្រួល ដោយសមាគមសម្រាប់កិច្ចសហប្រតិបត្តិការបច្ចេកទេសក្រៅប្រទេស និងភាពជាដៃគូប្រកបដោយនិរន្តរភាព (AOTS) និងសមាគមធុរកិច្ចទឹកអន្តរជាតិនៃខេត្តគីតាឃ្យូហ្សុ (KOWBA) ដែលមានសកម្មភាពដូចខាងក្រោម៖

❖ ថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៣៖ ក្រុមការងារសមាគមCWA បានចូលរួមទស្សនាទីតាំងប្រវត្តិសាស្ត្រ និងប្រសាទ Kokura Castle និងចូលរួមក្នុងវគ្គតម្រង់ទិស ដោយក្រុមការងារ AOTS និង KOWBA។

❖ ថ្ងៃទី១០ ខែមករា ឆ្នាំ២០២៣ ក្រុមការងារសមាគម CWA បានចូលរួមក្នុងកម្មវិធីដូចខាងក្រោម

ក. កិច្ចស្វាគមន៍ និងសំណេះសំណាលជាមួយសមាគម KOWBA

ខ. កិច្ចស្វាគមន៍ និងសំណេះសំណាលជាមួយថ្នាក់ដឹកនាំនៃរដ្ឋាករទឹកស្អាត និងទឹកស្អុយក្រុង Kitakyushu

គ. ទស្សនកិច្ចសិក្សាអំពី«វិធានការបង្ការការលេចធ្លាយទឹក» ដោយការិយាល័យចែកចាយ និងគ្រប់គ្រងទឹក នាយកដ្ឋានទឹកស្អាត រដ្ឋាករទឹកស្អាត និងទឹកស្អុយក្រុង Kitakyushu

ឃ. កម្មវិធីជួបជុំ និងកសាងទំនាក់ទំនងរវាងប្រតិភូប្រទេសកម្ពុជា និងសមាជិក KOWBA

❖ ថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣ ក្រុមការងារសមាគម CWA បានចូលរួមក្នុងកម្មវិធីដូចខាងក្រោម៖

ក. វគ្គបណ្តុះបណ្តាលស្តីពី«ប្រព័ន្ធគ្រប់គ្រងចែកចាយទឹក» ដោយការិយាល័យចែកចាយ និងគ្រប់គ្រងទឹក នាយកដ្ឋានទឹកស្អាត រដ្ឋាករទឹកស្អាត និងទឹកស្អុយក្រុង Kitakyushu នៅទីស្នាក់ការ កណ្តាលរដ្ឋាករទឹកស្អាត និងទឹកស្អុយ

ខ. វគ្គបណ្តុះបណ្តាលស្តីពី«ប្រព័ន្ធគ្រប់គ្រងទ្រព្យសកម្មដោយប្រើបច្ចេកវិទ្យាផែនទី» ដោយក្រុមហ៊ុន GEOCRAFT Co., Ltd នៅទីស្នាក់ការសមាគម KOWBA

គ. ទស្សនកិច្ចសិក្សាទៅកាន់រោងចក្រផលិតម៉ូទ័ររបស់ក្រុមហ៊ុន Eim Electric Co., Ltd Mizumaki Factory។



*រូបភាពទី ២៥ ការថតរូបអនុស្សាវរីយ៍*

❖ ៉ថ្ងៃទី១២ ខែមករា ឆ្នាំ២០២៣ ចូលរួមក្នុងកម្មវិធីដូចខាងក្រោម៖

ក. ធ្វើដំណើរពីទីក្រុងគីតាខ្យូហ្សុទៅកាន់ទីក្រុង Nagoya និងទស្សនារោងចក្រ Aichi Tokei ផលិតនាឡិកាទឹក

គ. ធ្វើដំណើរពីទីក្រុង Nagoya ទៅកាន់ទីក្រុងតូក្យូ។

❖ ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣ ចូលរួមក្នុងកម្មវិធីដូចខាងក្រោម៖

ក. សិក្សាស្វែងយល់អំពី«ការងារទឹកម៉ាស៊ីននៅជប៉ុន និងសមាគមទឹកម៉ាស៊ីនជប៉ុន»

ខ. ឆ្លុះបញ្ចាំងការរៀនសូត្រសម្រាប់រយៈពេល៥ថ្ងៃនៃវគ្គបណ្តុះបណ្តាល

គ. ចូលរួមពិធីចែកវិញ្ញាបនបត្របញ្ជាក់ការសិក្សា និងបិទវគ្គបណ្តុះបណ្តាល។

ជាលទ្ធផលក្រុមការងារ និងសមាជិកទាំងអស់ទទួលបានចំណេះដឹង និងបទពិសោធន៍ថ្មីជាច្រើនអំពី«ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត» និងវប្បធម៌របស់ប្រទេសជប៉ុនផងដែរ។ សមាគម CWA សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្មនៃរាជរដ្ឋាភិបាលជប៉ុនដែលបានឧបត្ថម្ភ និងសមាគមសម្រាប់កិច្ចសហប្រតិបត្តិការបច្ចេកទេសក្រៅប្រទេស និងភាពជាដៃគូប្រកបដោយនិរន្តរភាព( AOTS ) និង សមាគមធុរកិច្ចទឹកអន្តរជាតិនៃខេត្តគីតាខ្យូហ្សុ ( KOWBA )ដែលបានសហការរៀបចំ និងសម្របសម្រួល។



*រូបភាពទី ២៦ ក្រុមការងារសមាគម CWA នៅមុខការិយាល័យ (AOTS )*

## ៧. កិច្ចសហប្រតិបត្តិការ

ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ ក្រុមប្រឹក្សាភិបាល នាយកប្រតិបត្តិ និងសមាជិកសមាគមចំនួន ២៣ស្ថានីយ បានចូលរួមសិក្ខាសាលាស្តីពី«ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ កម្ពុជា-ជប៉ុន» លើកទី១៥ ដែលប្រធានបទសំខាន់នៅក្នុងឆ្នាំនេះគឺ«សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត នៃព្រះរាជាណាចក្រកម្ពុជា»។ សិក្ខាសាលានេះមានការអញ្ជើញចូលរួមជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អ៊ុំ សុថា** រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម... ក្រសួងឧវបន និងជាតំណាងដ៏ខ្ពង់ខ្ពង់ ឯកឧត្តមកិត្តិសេដ្ឋា បណ្ឌិត ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងឧវបន ក្នុងសិក្ខាសាលា មានចំនួនអ្នកចូលរួមប្រមាណ ១៦០នាក់។




*រូបភាពទី ២៧ រូបថតអនុស្សាវរីយ៍ ក្រោយបញ្ចប់វគ្គសិក្ខាសាលា*

ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា បានចូលរួមសន្និបាតប្រចាំឆ្នាំ២០២២ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៅទីស្តីការក្រសួង។ ក្នុងឱកាសនោះដែរ **លោក ហម ងួន** អនុប្រធានក្រុមប្រឹក្សាភិបាល បានធ្វើបទអន្តរាគមន៍ស្តីពីសមិទ្ធិផលការងារសមាគមឆ្នាំ២០២២ បញ្ហា និងសំណូមពរ សុំឱ្យក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជួយសម្របសម្រួលជាមួយក្រសួងពាក់ព័ន្ធ ជាពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចខាងក្រោម៖

- សុំឱ្យមានសំណងផលប៉ះពាល់ពេលខូចខាតបំពង់ទឹកស្អាត
- សុំលើកលែងការបង់ពន្ធលើប្រាក់ចំណូល
- សុំលើកលែងការបង់ពន្ធអាករលើតម្លៃបន្ថែម (VAT) លើថ្លៃតំណ
- សុំឱ្យមានកម្ចីដែលមានការប្រាក់ទាប និងងាយស្រួលសម្រាប់វិស័យទឹកស្អាត។




*រូបភាពទី ២៨ លោក ហម ងួន អនុប្រធានក្រុមប្រឹក្សាភិបាល ធ្វើបទអន្តរាគមន៍ក្នុងពិធីបិទសន្និបាតក្រសួង ឧវបន*

## ៨. ការសម្របសម្រួលទស្សនកិច្ចសិក្សារបស់គណៈប្រតិភូប្រទេសអាល្លឺម៉ង់

ព្រឹកថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា បានសម្របសម្រួលដឹកនាំគណៈប្រតិភូអាល្លឺម៉ង់ ដែលអញ្ជើញមកធ្វើទស្សនកិច្ចសិក្សាពីប្រព័ន្ធទឹកស្អាត និងប្រព័ន្ធទឹកកខ្វក់ នៅកម្ពុជា បានចូលជួបសម្តែងការគួរសមជាមួយថ្នាក់ដឹកនាំក្រសួងឧវបន។ ការជួបសម្តែងការគួរសមនេះប្រព្រឹត្តក្រោមអធិបតីភាព **ឯកឧត្តម អ៊ុំ សុថា** រដ្ឋលេខាធិការ ក្រសួងឧវបន និងជាតំណាងដ៏ខ្ពង់ខ្ពស់ របស់ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិតទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងឧវបន។



*រូបភាពទី ២៩ ការថតរូបអនុស្សាវរីយ៍ របស់គណប្រតិភូអាល្លឺម៉ង់ក្រោយបញ្ចប់ការសម្តែងការគួរសម*

រសៀលថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣ គណៈប្រតិភូអាល្លឺម៉ង់បានជួបប្រជុំជាមួយរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដើម្បីស្វែងយល់ពីប្រវត្តិ ដំណើរការផលិត និងការផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋ ព្រមទាំងធ្វើទស្សនៈកិច្ចសិក្សានៅរោងចក្រផលិតទឹកស្អាតភូមិព្រែក ក្នុងស្វែងយល់អំពីចង្វាក់ផលិតកម្ម និងការផ្គត់ផ្គង់ទឹកស្អាតរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។ ជាមួយគ្នានេះសមាគមសូមថ្លែងអំណាគុណដល់ **លោក ម៉ា ណូរ៉ាវីន** អគ្គនាយករង នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលបានទទួលស្វាគមន៍ ក្រុមការងារ និងគណៈប្រតិភូយ៉ាងកក់ក្តៅ ព្រមទាំងធ្វើបទបង្ហាញអំពីប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។



*រូបភាពទី ៣០ ការថតរូបអនុស្សាវរីយ៍ ជាមួយលោក ម៉ា ណូរ៉ាវីន អគ្គនាយករង រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ*

ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ គណៈប្រតិភូអាល្លឺម៉ង់បានធ្វើទស្សនកិច្ចសិក្សានៅរោងចក្រផលិតស្វាយ នៅគីរីវម្យ ខេត្តកំពង់ស្ពឺ ដើម្បីស្វែងយល់ពីរោងចក្រប្រព្រឹត្តកម្មទឹកកខ្វក់។



*រូបភាពទី ៣១ ការទស្សនារោងចក្រប្រព្រឹត្តកម្មទឹកកខ្វក់នៅខេត្តកំពង់ស្ពឺ*

ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ សមាគមបានរៀបចំសិក្ខាសាលាស្តីពី«ប្រព័ន្ធប្រព្រឹត្តកម្មទឹកស្អាត និងទឹកកខ្វក់ កម្ពុជា-អាឡឺម៉ង់» នៅសណ្ឋាគារ Palace Gate។



*រូបភាពទី ៣២ រូបភាពអនុស្សាវរីយ៍ក្រោយបញ្ចប់វគ្គសិក្ខាសាលា*

ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ សមាគមបានរៀបចំកិច្ចពិភាក្សាតុមូល ដើម្បីស្វែងយល់អំពី យុទ្ធសាស្ត្រថ្នាក់ជាតិសម្រាប់វិស័យទឹកស្អាត និងទឹកកខ្វក់នៅកម្ពុជា រវាងគណៈប្រតិភូប្រទេសអាល្លឺម៉ង់ និងតំណាងក្រសួងឧវបន ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួង

ធនធានទឹក និងឧត្តុនិយម។ ជាលទ្ធផលគណៈប្រតិភូបានស្វែងយល់អំពីទិដ្ឋភាពទូទៅ គោលការណ៍ យុទ្ធសាស្ត្រ និងផែនការរបស់ក្រសួងទាំង៤ សម្រាប់វិស័យទឹកស្អាត និងទឹកកខ្វក់នៅប្រទេសកម្ពុជា។




*រូបភាពទី ៣៣ ការធ្វើបទបង្ហាញរបស់ ឯកឧត្តម ស្រេង សុខវង្ស ទីប្រឹក្សាបច្ចេក ក្រសួង ឧវបន*

ថ្ងៃទី០២ ខែមីនា ឆ្នាំ២០២៣ គណៈប្រតិភូអាល្លឺម៉ង់បានបានធ្វើទស្សនកិច្ចសិក្សានៅអង្គភាពរដ្ឋាករទឹកកំពង់ធំ និងស្ថានីយទឹកស្អាតស្រុកសូទ្រនិគម ដើម្បីស្វែងយល់ពីប្រព័ន្ធប្រព្រឹត្តកម្មទឹកស្អាត។




*រូបភាពទី ៣៤ ទស្សនកិច្ចសិក្សានៅអង្គភាពរដ្ឋាករទឹក កំពង់ធំ*



*រូបភាពទី ៣៥ ទស្សនកិច្ចសិក្សានៅស្ថានីយទឹកស្អាតស្រុកសូទ្រនិគម*

ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២៣ គណៈប្រតិភូអាល្លឺម៉ង់បានធ្វើទស្សនកិច្ចសិក្សានៅអង្គភាពរដ្ឋាករទឹកស្វយ័តសៀមរាប និងប្រព័ន្ធសម្អាតទឹកកខ្វក់របស់ក្រុងសៀមរាប។




*រូបភាពទី ៣៥ កិច្ចប្រជុំនៅរោងចក្រសម្អាតទឹកកខ្វក់ ក្រុងសៀមរាប*